# ខ្លីៗអំពីកម្ពុជា

ការវិវឌ្ឍក្នុងទសវត្សរ៍កន្លងមកគេឃើញថា សេដ្ឋកិច្ចកម្ពុជាមានភាពរឹងមាំទោះស្ថិតនៅក្នុងស្ថានភាព សេដ្ឋកិច្ចអន្តរជាតិ ប្រកបដោយ បញ្ហាត្រូវប្រឈមមុខជាច្រើនក្តី ។ គេប្រមាណឃើញថាកំណើនសេដ្ឋកិច្ច កម្ពុជាក្នុងឆ្នាំ២០០១ ស្មើនឹង ៦,៣% ជំរុញដោយវិស័យ ទេសចរណ៍ដែលកំពុងរីកចំរើន និងនីហរណកម្ម សំលៀកបំពាក់ដ៏រឹងមាំ ។ អតិផរណាក្នុងឆ្នាំ ២០០១ ស្មើរតែស្មើសូន្យ ហើយមកទល់និង ឆ្នាំ២០០២ អតិផរណានៅមានកំរិតទាបដដែល ។ ការអនុវត្តថវិកាជាតិឆ្នាំ២០០១ កាន់តែមានភាពប្រសើរឡើងក្នុងនោះចំណូលបាន កើនឡើងបន្តិច ហើយក៏មានការប្តូរទិសខ្លះៗ ក្នុងផ្នែកចំណាយសាធារណៈ ទៅរកវិស័យសង្គមសំខាន់ៗដែរ ។ ការព្យាករសំរាប់ឆ្នាំនេះ ជាទូទៅមានភាពអនុគ្រោះល្អឯកំណើនផលិតផលក្នុងស្រុក សរុបជាគោលដៅរបស់រដ្ឋាភិបាលគឺ ៥,៥% ។

ក្នុងឆ្នាំកន្លងមកនេះ រដ្ឋាភិបាលបានជំរុញអោយមានការវិវឌ្ឍ គួរអោយកត់សំគាល់នៅក្នុងវិស័យមួយចំនួន ។ នាដើមឆ្នាំនេះ រដ្ឋសភាជាតិបាន អនុមតិផែនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចលើកទីពីរ (ផអសស២) ដែលជាគ្រឹះយ៉ាងមាំសំរាប់ការកាត់បន្ថយ ភាពក្រីក្រ ។ ផអសស២ និង ឯកសារស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រក្នុង អន្តរកាលបានផ្តល់រចនាសំព័ន្ធគោលសំរាប់ផែនការសកម្មភាពពិត ដើម្បីកាត់បន្ថយភាព ក្រីក្រ ។ ក្នុងឆ្នាំកន្លងទៅនេះ រដ្ឋាភិបាលក៏បានជំរុញអោយមានការវិវឌ្ឍ គួរអោយកត់សំគាល់ផងដែរ ក្នុងការបង្កើតយុទ្ធសាស្ត្រនានា សំរាប់ឈានទៅមុខលើវិស័យគន្លឹះមួយចំនួនរួមមានវិស័យអប់រំ សុខាភិបាល អភិបាលកិច្ចល្អ និងការផ្គត់ផ្គង់អាហាររូបត្ថម្ភ។ គេបានបំពេញបន្ថែមទៅលើសកម្មភាពទាំងនោះ ដោយការខំប្រឹងប្រែងកែលំអ ចំណាយសាធារណៈ និងការគ្រប់គ្រងចំណូលព្រមទាំងការកំណត់គោលការ ចំណាយរយៈពេលមធ្យម។

<u>បញ្ហាចំពោះមុខនានាក្នុងពេលបច្ចុប្បន្ន</u>

មកទល់ពេលនេះកម្ពុជាបានជួបប្រទះនឹងបញ្ហាលំបាកជាច្រើនដែលត្រូវជំនះដើម្បីអភិវឌ្ឍន៍ ។ កម្ពុជាជាប្រទេសក្រោយទំនាស់មួយ ដែល មានមូលដ្ឋានគ្រឹះជាច្រើនសំរាប់ការរីកចំរើន និងអភិវឌ្ឍន៍ (សំភារៈ សង្គមមនុស្ស និងសេដ្ឋកិច្ច) រងការបំផ្លាញ និងចាំបាច់ត្រូវស្តារឡើង វិញ ។ ទើបតែពេលថ្មីៗនេះទេ ដែលគេអាចចូលទៅដល់ផ្នែកជាច្រើននៃផ្ទៃប្រទេស គឺក្រោយពេលស្ថានភាព សន្តិសុខបាន ធូរស្រាល ។ រដ្ឋាភិបាលមិនទាន់មានធនធានគ្រប់គ្រាន់នៅឡើយ សំរាប់វិនិយោគអោយបានសមស្រប ទៅក្នុងវិស័យសុខាភិបាល និងអប់រំ ឬ ទៅ លើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ ចំណូលប្រចាំឆ្នាំក្នុងម្នាក់ៗស្មើនឹង ២៩០ដុល្លាអាមេរិក។ ថ្វីបើភាពក្រីក្រ បានថយចុះបន្តិច ចាប់ពីឆ្នាំ ១៩៩៣-៩៤ (៣៩% នៃចំនួនប្រជាជនសរុប) មុនដំបូងនៅរាជធានីភ្នំពេញ ហើយបន្តបន្ទាប់មក នៅតាមក្រុង ទីរួមខេត្តនានា ការប្រមាណថ្មីៗនេះ អំពីភាពក្រីក្របានបង្ហាញថា ៣៦% នៃប្រជាជនទាំងអស់ រស់នៅក្រោមខ្សែ

សន្ទស្សន៍ភាពក្រីក្រនៅឡើយក្នុងនោះ ៩០% រស់នៅតាមជនបទ គេឃើញថា អត្រាភាពក្រីក្រខ្ពស់ជាងគេ ស្ថិតនៅក្នុងចំណោមគ្រួសារ ដែលមានប្រភពចំណូលពីរបរកសិកម្ម ។

យោងតាមប្រវត្តិសាស្ត្រចុងក្រោយនេះ ប្រទេសកម្ពុជាមានក្រុមប្រជាជនទន់ខ្សោយច្រើនពន់ពេក ក្នុងនោះមានប្រជាជនដែលផ្លាស់ទីលំនៅ ក្នុងប្រទេស និងជនភៀសខ្លួនដែលត្រលប់មកវិញ ស្ត្រីមេម៉ាយដោយសារសង្គ្រាម ក្មេងកំព្រា កូនអតីតយុទ្ធជន និងជនពិការ ដោយសារ សង្គ្រាម និងដោយសារមីន។ មនុស្សម្នាក់ក្នុងចំណោមប្រជាជន ២៥០នាក់ គឺជាជនពិការ ឯសមាមាត្រនៃជនពិការអាវះយវះ គឺម្នាក់ ក្នុងចំណោម ៣៨៤នាក់ នេះជាតួលេខខ្ពស់បំផុតនៅក្នុងពិភពលោក។ ស្ត្រីទាំងឡាយទទួលបន្ទុកយ៉ាងអស់សមាមាត្រក្នុងការថែទាំ ជនពិការ ។

អត្រាពលកម្មកុមារ ការជួញដូរស្ត្រី និងកុមារឆ្លងព្រំដែន ព្រមទាំងការផ្លាស់ទីលំនៅស្របច្បាប់ និងកំណើន ដ៏រហ័សនៃឧស្សាហកម្ម ជំនួញផ្លូវភេទបានឆ្លុះបញ្ចាំងអោយឃើញពីការលំបាកជាច្រើនដែលក្រុមជនក្រីក្រ និង ទន់ខ្សោយទាំងឡាយ ជាពិសេសស្ត្រីត្រូវប្រឈមមុខ ដើម្បីធានាអោយបាននូវជីវភាព ដ៏មានស្ថិរភាពមួយ ។ កំណើនអត្រានៃការឆ្លង ហ៊ីវ-អេដស៍ ជាការគំរាមកំហែងដ៏ធន់ធ្ងរមួយ ។ ជនក្រីក្រទាំងឡាយ ជាពិសេសអ្នកស្ថិតក្នុងក្រុមទន់ខ្សោយជាងគេ គ្មានសំលេង គ្មានលទ្ធភាពទទួលសេវា និងឱកាសនានាឡើយ ។ ទាំង ធនធានមនុស្ស ទាំងសំភារៈ បានរួញចុះតិចតួចទៅៗ នៅក្នុងបណ្តាទសវត្សរ៍នៃទំនាស់ កន្លងមកនេះ បណ្តាលអោយមានការកំហិត លទ្ធភាពជាខ្លាំង ហើយអាំងឌីកាទ័រសង្គមទាំងឡាយស្ថិតក្នុងចំណោម អ្នកអន់ជាងគេនៅក្នុងតំបន់។

ធនធានសង្គម ដែលរងការបំផ្លាញដោយសារទំនាស់ ក៏ត្រូវតែស្តារឡើងវិញដែរ ឯជំនឿចិត្តទៅលើស្ថាប័នសាធារណៈនានា ក៏ត្រូវកសាង ឡើងវិញដែរ ។ ការចោទប្រកាន់ទៅលើអំពើពុករលួយ និងភាពគ្មានទោស ពៃរ៍ត្រូវគេដឹងជាទូទៅ ។ ផ្នែកឯកជនដែលជាកំលាំងនាំមុខគេ ក្នុងការស្តារសេដ្ឋកិច្ចប្រទេស នៅតាមជនបទ និងទីក្រុងនានា និងមានសារៈសំខាន់ជាខ្លាំង ចំពោះប្រសិទ្ធភាព នៃការកាត់បន្ថយភាព ក្រីក្រត្រូវរងការទប់បង្អាក់ដោយសារ ហេដ្ឋារចនាសម្ព័ន្ធមានកំរិត និងមានថ្លៃខ្ពស់ ច្បាប់ដីនិងច្បាប់កម្មសិទ្ធិមិនប្រាកដប្រជា លទ្ធភាពទទួល ឥណទានមានកំរិត និងដោយសាររចនាសំព័ន្ធ គោលរបស់ច្បាប់នៅទន់ខ្សោយ និងប្រែប្រួល រកស្ថានមិនត្រូវ ។

## ការប្រយុទ្ធនឹងភាពក្រីក្រ

ជាការឆ្លើយតបទៅនឹងបញ្ហាចំពោះមុខទាំងនេះ អ្នកដឹកនាំកម្ពុជាទាំងឡាយ បានសន្យាថានឹងកែលំអជីវភាពរបស់ប្រជាជនកម្ពុជា ពោលគឺ ប្រយុទ្ធនឹងភាពក្រីក្រ ព្រមទាំងកសាងឡើងវិញនូវហេដ្ឋារចនាសំព័ន្ធសង្គម និងសេដ្ឋកិច្ច ។ ពួកគេកំពុងខិតខំកសាងរចនាសម្ព័ន្ធគោលនៃ ម៉ាក្រូសេដ្ឋកិច្ច និងសំរេចបានការវិវឌ្ឍក្នុងការបង្កើនប្រាក់ចំណូលគួរអោយសរសើរ ។ ពួកគេបានចាប់ផ្តើមធ្វើកំណែទំរង់ដ៏លំបាកជាច្រើន ក្នុងវិស័យសាធារណៈការ (គ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំស្ថាប័នរដ្ឋឡើងវិញ និងការកាត់បន្ថយកងទ័ព) ហើយបានយល់ព្រមអោយអ្នកផ្តល់ ជំនួយក្នុងប្រទេស

និងអន្តរជាតិទាំងឡាយ ត្រួតពិនិត្យការកែទំរង់នោះយ៉ាងជិត ។ ការពិគ្រោះយោបល់ ប្រចាំឆមាសរវាងរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី និងការរៀបចំប្រជុំតាម កិច្ចសន្យានានា ក្នុងពេលថ្មីៗនេះ ជាមួយអង្គការក្រៅ រដ្ឋាភិបាលអន្តរជាតិមានកិត្តិស័ព្ទល្អ ដើម្បីត្រួតពិនិត្យការវិវឌ្ឍក្នុងវិស័យកំណែទំរង់ព្រៃឈើ គឺជាអាំងឌីកាទ័រដ៏សំខាន់ដែលបញ្ជាក់ ពីចេតនាចង់ចូលរួមរបស់អ្នកដឹកនាំជាន់ខ្ពស់បំផុតទាំងឡាយ ។ ការសន្ទនាជាមួយផ្នែកអាជីវកម្ម ឯកជនទាំងឡាយ និងសង្គមស៊ីវិល កំពុង តែកើនច្រើនឡើងៗ។ កម្ពុជាមានសក្តានុពលក្នុងការទាញប្រយោជន៍អំពីប្រភពនៃការរីកចំរើននានាដូចជាកសិកម្ម ធនធានធម្មជាតិ ឧស្សាហ កម្មធុនស្រាល និងវប្បធម៌-ទេសចរណ៍ ។ លទ្ធភាពរបស់កម្ពុជាក្នុងការទាញប្រយោជន៍អំពីកត្តាទាំងនេះ អាស្រ័យមួយផ្នែកលើការ ចាប់ផ្តើមដោះស្រាយភាពមានកំរិតនៃធនធានសំភារៈ និងមនុស្ស ហើយជាបឋម វាអាស្រ័យនឹងការរក្សាសំទុះ នៃការកែទំរង់ទាំងនោះ របស់រដ្ឋាភិបាល ។ ថ្វីបើការកែទំរង់ អាចទាមទារពេលរាប់ឆ្នាំក្តី វាចាំបាច់ណាស់ចំពោះការទាក់ទាញការវិនិយោគ ការសន្សំសំចៃ ព្រមទាំង ការនាំកម្ពុជាទៅតាមផ្លូវនៃការរីកចំរើនប្រកបដោយនិរន្តរភាព ដែលនឹងជួយកាត់បន្ថយភាពក្រីក្រ ។

## ការឧបត្ថម្ភរបស់ធនាគារពិភពលោកដល់កម្ពុជា

ធនាគារពិភពលោក កំពុងជួយកម្ពុជាក្នុងការកសាងគ្រឹះនានា សំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ។ ការកសាងគ្រឹះទាំងនេះមានន័យថា:

- ការគាំទ្រអភិបាលកិច្ចល្អដូចជាកំណែទំរង់និតិកម្ម និងតុលាការ កំណែទំរង់វិស័យសាធារណៈរួមមាន ការរៀបចំរដ្ឋបាលស៊ីវិលឡើងវិញ និងការកាត់បន្ថយកងទ័ព ។
- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសផ្លូវថ្នល់ការផ្គត់ផ្គង់ទឹក និងអគ្គិសនីនៅតាមតំបន់ជនបទ និងខេត្តទាំងឡាយ ដើម្បីបង្កើន លទ្ធភាពទទួលសេវានានា និងសកម្មភាពផលិតកម្ម ។
- ការកសាងធនធានមនុស្សតាមរយៈការបង្កើនលទ្ធភាព ទទួលសេវាថែទាំសុខភាពនានា ប្រកបដោយគុណភាព និងការវិនិយោគ ក្នុងការ អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនឹងចូលរួមកសាងសមត្ថភាពកំរិតអន្តរជាតិ និង អភិបាលកិច្ចល្អ ក៏ដូចជាការទទួលបានលទ្ធផល ផ្នែកសុខភាពល្អជាងមុន ការបង្កើតចំណូល និងលទ្ធភាពប្រកួតប្រជែង ។

- ការសំរួលដល់ការអភិវឌ្ឍផ្នែកឯកជន ក្នុងវិស័យជាប្រពៃណី និងមិនមែនជាប្រពៃណីរួមមាន ការគាំទ្រ ការបង្កើតចំណូល នៅតាមជនបទ តាមរយៈការផ្លាស់បញ្ចូលគ្នានូវគោលនយោបាយការងារ ការលើកទឹកចិត្តជាប្រចាំ ចំពោះការសន្ទនាស្ថាបនា រវាងរដ្ឋាភិបាល និងផ្នែកឯកជន ព្រមទាំងផ្តល់ការគាំទ្រផ្ទាល់ ដល់អាជីវកម្មជំនួញនានា ។

អន្តរាគមន៍ទាំងអស់របស់ធនាគារពិភពលោកផ្តោតជាខ្លាំងតាមដែលអាចធ្វើទៅបាន ទៅលើតំបន់ជនបទទាំងឡាយ ដែលនៅទីនោះមាន ជនក្រីក្រភាគច្រើន និងភាគច្រើននៃប្រជាជនទាំងមូលរស់នៅ និងទៅលើការបង្កើនលទ្ធភាព

និងឱកាសដល់ស្ត្រី ជាពិសេសក្នុងការទទួលបាន ការអប់រំ ។ ក្រុមធនាគារនឹងចាប់អារម្មណ៍ជាពិសេស ក្នុងការបញ្ចូលទៅក្នុងមូលដ្ឋាននៃសក្តានុពល សំរាប់ការរីកចំរើន នូវក្រុមប្រជាជន ទន់ខ្សោយទាំងឡាយ និង ការអភិរក្ស និងស្តារឡើងវិញនូវធនធានធម្មជាតិ ដែលប្រទេសនេះ មានព្រមទាំងមរតកវប្បធម៌ទាំងឡាយ ។ ការកសាងសមត្ថភាពគឺជាផ្នែករួមបញ្ចូលគ្នាមួយរបស់អន្តរាគមន៍ទាំងអស់នេះ ។

<u>ការជួយកម្ពុជាក្នុងការបញ្ចូលអតីតយុទ្ធជនទាំងឡាយមកក្នុងសហគមន៍របស់ពួកគេវិញ</u>

ធនាគារពិភពលោក កំពុងជួយគាំទ្រដល់ការខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីកាត់រំសាយកងទ័ពចំនួន ៣០ ០០០ នាក់ និងលើកទឹកចិត្ត ដល់ការវិលត្រឡប់ដោយជោគជ័យមករស់នៅក្នុងជីវភាពជាស៊ីវិលវិញ ។ គំរោងមានបំណងជួយរដ្ឋាភិបាល ក្នុងការសំរេចបន្ថយចំនួន កងទ័ពប្រមាណមួយភាគបី ។ គំរោងនេះនឹងចូលរួមបង្វែរប្រភពថវិកា ដែលជាលទ្ធផលនៃការសំចៃ បានពីការកាត់រំសាយកងទ័ពទៅឱ្យវិស័យអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ។ ជាបន្ថែមទៅលើប្រាក់ឥណទានចំនួន ១៨,៤លានដុល្លាអាមេរិក បានមកពី សមាគមអភិវឌ្ឍន៍អន្តរជាតិ គំរោងកាត់បន្ថយ និងបញ្ចូលកងទ័ពមកជាស៊ីវិលវិញបាន ទទួលមូលនិធិ ពីប្រទេសជប៉ុន (១០លាន ដុល្លាអាមេរិក) ស៊ុយអែត (២,៤លាន ដុល្លាអាមេរិក) ហូឡង់ (២លាន ដុល្លាអាមេរិក) និងកម្មវិធីស្បៀងអាហារពិភពលោក (២លាន ដុល្លាអាមេរិក) ព្រមទាំង ៧,២លាន ដុល្លាអាមេរិក ពីរដ្ឋាភិបាលកម្ពុជាផ្ទាល់ ។ ជាបន្ថែមលើការបញ្ចូលយុទ្ធជនចំនួន ៣០ ០០០ មក កាន់ជីវភាពជាស៊ីវិលវិញ នោះគំរោងកាត់បន្ថយ និងបញ្ចូលកងទ័ពមកជាស៊ីវិលវិញ មានបំណងជួយរដ្ឋាភិបាល ក្នុងការបង្វែរមូលនិធិ ទៅអោយវិស័យសង្គមនានា ។ វាជាការសំខាន់ណាស់ ដែលអតីតយុទ្ធជនដែលត្រលប់មកកាន់ជីវភាពជាស៊ីវិលវិញ មានឱកាសរស់ នៅក្នុងជីវភាពផលិតកម្ម ។ ជាបន្ថែមទៅលើសេចក្តីត្រូវការនានាក្នុងជីវិតដូចជាស្បៀងអាហារ និងទីជំរកអតីតយុទ្ធជន ទាំងឡាយនឹង ត្រូវការការផ្តល់យោបល់ សំរាប់ការឈានចូលដោយជោគជ័យ ទៅក្នុងសហគមន៍នានារបស់ពួកគេវិញ ។ ការតាមដានពិនិត្យ យ៉ាងប្រុង ប្រយ័ត្ន គឺជាគន្លឹះសំរាប់ធានាថាអតីតយុទ្ធជនទាំងឡាយ គ្រួសាររបស់ពួកគេ និងសហគមន៍ទាំងឡាយ នឹងទទួលបាន ផលប្រយោជន៍ទាំងអស់គ្នា ។

លោកស្រី នីសា អាក្រាវ៉ាល

ការិយាល័យ : ផ្ទះលេខ ១១៣ មហាវិថីព្រះនរោត្តម ភ្នំពេញ

ទូរស័ព្ទ: (855-23) 213-538

ទូរសារ: (855-23) 210-504

អ៊ីមែល: nagrawal@worldbank.org